01121941

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception):
29 / 07 / 2015
ម៉ោង (Time/Heure) : 15:20
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E354

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

សាធារណៈ / Public

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៥

**ជូនចំពោះ៖** គ្រប់ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃ អង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** អង្គជំនុំជម្រះសាលាដំបូងដាក់ផែនទីបន្ទប់សវនាការនៅក្នុងសំណុំរឿង តាមគំនិតផ្តួចផ្តើមរបស់ខ្លួន

1. នៅក្នុងករណីខ្លះ ក្នុងអំឡុងកិច្ចដំណើរការនីតិវិធីសវនាការសំណុំរឿង ០០២/០២ ចម្ងាយពីកន្លែងដែលសាក្សីអង្គុយ ទៅអាសនៈចៅក្រម ត្រូវបានប្រើប្រាស់ជាការប៉ាន់ប្រមាណចម្ងាយ នៅក្នុងអំឡុងពេលផ្តល់សក្ខីកម្ម (សូមមើល ប្រតិចារឹក ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ៣៦, ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ៣-៤)។ ជាក់ស្តែង ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ដែលធ្លាប់ធ្វើការនៅសហករណ៍ត្រាំកក់ បានផ្តល់សក្ខីកម្មថា គាត់បានឃើញជនជាប់ចោទ រួមជាមួយនឹងមេដឹកនាំកម្ពុជាប្រជាធិបតេយ្យផ្សេងទៀត រួមមាន ប៉ុល ពត និង តា ម៉ុក បានចុះទៅទស្សនកិច្ចការដ្ឋានដែលគាត់ធ្វើការ ហើយគម្លាតពីគាត់ទៅកាន់អ្នកទាំងនោះ មានចម្ងាយប្រហែលពីកន្លែងគាត់កំពុងអង្គុយផ្តល់សក្ខីកម្ម ទៅកន្លែងអាសនៈរបស់ចៅក្រម។ យោងតាមផ្នែករដ្ឋបាលតុលាការ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ចម្ងាយនេះមានប្រវែងប្រហែល ៩ ម៉ែត្រ និង បានបញ្ជាក់ថា អង្គជំនុំជម្រះនឹងដាក់ព័ត៌មាននេះ ទៅក្នុងសំណុំរឿង ដើម្បីទុកជាឯកសារយោងនាពេលខាងមុខ (ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ៣-៤)។

2. គំនូសដែលបានភ្ជាប់ជាមួយនេះ (ឯកសារ E354.1) កំណត់ចម្ងាយពីកន្លែងសាក្សីអង្គុយផ្តល់សក្ខីកម្មទៅអាសនៈប្រធានអង្គជំនុំជម្រះ រួមទាំងចម្ងាយពីកន្លែងសាក្សីនេះ ទៅចំណុចយោងពីរផ្សេងទៀត ដោយមានបញ្ជាក់នូវរង្វាស់ចម្ងាយប្រហាក់ប្រហែល។ ដោយសារមានការយោងទៅលើចម្ងាយពីកន្លែងសាក្សីអង្គុយ ទៅអាសនៈចៅក្រម នៅក្នុងការផ្តល់សក្ខីកម្មផ្ទាល់មាត់ក្នុងអំឡុងសវនាការ ហើយថា ចម្ងាយដែលបង្ហាញនៅក្នុងគំនូសនេះ អាចត្រូវបានប្រើប្រាស់ដើម្បីកំណត់អំពីប្រវែង និង ចម្ងាយ នៅក្នុងការផ្តល់សក្ខីកម្មនាពេលខាងមុខទៀតនោះ អង្គជំនុំជម្រះសាលាដំបូងសម្រេចដាក់គំនូសនេះទៅក្នុងសំណុំរឿងតាមគំនិតផ្តួចផ្តើមរបស់ខ្លួនអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។